**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

NATIONAL ACCOUNTING COUNCIL
ក្រុមប្រឹក្សាជាតិគណនេយ្យ ក.ជ.គ. NAC

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**ក្រុមប្រឹក្សាជាតិគណនេយ្យ**
លេខ...០០៧...... ក.ជ.គ........

ថ្ងៃព្រហស្បតិ៍ ២រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ១២ ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យអនុវត្តសាកល្បងនៃកម្មវិធីឃ្លាំមើលរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម, អនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និង ប្រកាសលេខ ៥៦៣ សហវ.ប្រក ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ, ក្រុមប្រឹក្សាជាតិគណនេយ្យសូមជម្រាបជូនដំណឹងដល់ម្ចាស់សហគ្រាស និងសាធារណៈជនទាំងអស់ឱ្យបានជ្រាបថា ក្រុមប្រឹក្សាជាតិគណនេយ្យបានសម្រេចដាក់ឱ្យអនុវត្តសាកល្បងនូវកម្មវិធីឃ្លាំមើលរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ នឹងចាប់ផ្តើមអនុវត្តកម្មវិធីនេះដោយធ្វើការជ្រើសរើសរបាយការណ៍-ហិរញ្ញវត្ថុរបស់សហគ្រាសយ៉ាងតិចចំនួន១០ សម្រាប់ការិយបរិច្ឆេទគណនេយ្យមុនឆ្នាំ២០២០ ដែលសហគ្រាសបានបញ្ជូនមកក្រុមប្រឹក្សាជាតិគណនេយ្យ។

គោលបំណងនៃការដាក់ឱ្យអនុវត្តកម្មវិធីនេះ គឺដើម្បីត្រួតពិនិត្យពីកម្រិតអនុលោមភាពនៃរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស ធៀបនឹងលក្ខខណ្ឌតម្រូវចាំបាច់នានាដែលច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់-ព័ន្ធបានកំណត់។ ក្នុងដំណាក់កាលសាកល្បងនេះ, ក្រុមប្រឹក្សាជាតិគណនេយ្យនឹងមិនអនុវត្តទោសទណ្ឌឡើយលើសហគ្រាសណាមួយដែលលទ្ធផលនៃការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុបង្ហាញថាមិនបានអនុលោម ឬបានអនុលោមតិចតួចតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៅឡើយទេ ។

ក្រោយការអនុវត្តសាកល្បង, កម្មវិធីឃ្លាំមើលរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសនឹងអាចត្រូវបានកែសម្រួលជាបន្តបន្ទាប់តាមការចាំបាច់។

អាស្រ័យហេតុនេះ សូមម្ចាស់សហគ្រាស និងសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន។

**ក្រុមប្រឹក្សាជាតិគណនេយ្យ**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
Website: www.naccambodia.gov.kh
Email : info@naccambodia.gov.kh
ទូរស័ព្ទ: ៨៥៥-២៣ ៤៣២ ១៥៤/៨៥៥-២៣ ៤៣២ ១៧៤
Phone: 023 432 154 / 023 432 174

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# កម្មវិធីឃ្លាំមើល
# របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស

**មាតិកា** **ទំព័រ**


I. សេចក្តីផ្តើម ២

II. គោលបំណងនៃកម្មវិធី ២

III. នាយកដ្ឋានអនុវត្ត ៣

IV. មុខងារ និងភារកិច្ច ៣

V. ចំណុចវាយតម្លៃ ៥

VI. ទោសទណ្ឌ ៧




ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
Website: www.naccambodia.gov.kh
Email : info@naccambodia.gov.kh
ទូរស័ព្ទ: ៨៥៥-២៣ ៤៣២ ១៥៤ / ៨៥៥-២៣ ៤៣២ ១៧៤
Phone: 023 432 154 / 023 432 174

## I. សេចក្តីផ្តើម

ក្រុមប្រឹក្សាជាតិគណនេយ្យ ជានិយ័តករនិងជាសេនាធិការរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលគ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្មនៅព្រះរាជាណាចក្រកម្ពុជា។

ព័ត៌មានហិរញ្ញវត្ថុប្រកបដោយគុណភាពមានសារៈសំខាន់ណាស់សម្រាប់ទីផ្សាររឹងមាំនិងរស់រវើក។ លើសពីនេះ វិនិយោគិន, អ្នកផ្គត់ផ្គង់, ស្ថាប័នហិរញ្ញវត្ថុ,អតិថិជន, នាយកប្រតិបត្តិក្រុមហ៊ុន, និងក្រុមហ៊ុនជាច្រើនទៀតកំពុងស្វែងរករបាយការណ៍ហិរញ្ញវត្ថុ ដែលអាចទុកចិត្តបាន និងទាន់ពេលវេលាដើម្បីទទួលបានរូបភាពអាជីវកម្មកាន់តែច្បាស់មិនថាទាក់ទងនឹងការបង្កើតតម្លៃបន្ថែម ឬការស្វែងយល់ហានិភ័យពាក់ព័ន្ធនោះទេ។

ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកអាជីវកម្មក៏កាន់តែមានបញ្ហាប្រឈម និងស្មុគស្មាញកាន់តែច្រើន។ ដើម្បីទប់ទល់កុំឱ្យស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុមានភាពស្មុគស្មាញកាន់តែខ្លាំង ហើយទាមទារឱ្យមានការវិនិច្ឆ័យវិជ្ជាជីវៈបន្ថែមទៀតនៃអ្នករៀបចំរបាយការណ៍ហិរញ្ញវត្ថុ, ការជួញដូរអាជីវកម្ម ការត្រូវវាស់តម្លៃត្រឹមត្រូវនៃទ្រព្យសកម្ម និងការទទួលស្គាល់ចំណូលនៃប្រតិបត្តិការជាច្រើនទៀត។

យើងពិតជាត្រូវការចាំបាច់ណាស់ឱ្យទីផ្សារផ្តល់ទំនុកចិត្ត, តម្លាភាព, សុចរិតភាព និងគុណភាពនៃរបាយការណ៍ហិរញ្ញវត្ថុ។ ម្យ៉ាងវិញទៀត,ផ្អែកលើការអង្កេត ក្រុមហ៊ុននៅកម្ពុជាបច្ចុប្បន្នមានចំនួនតិចណាស់ដែលបានអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធ ដូចនេះដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនេះក្រុមប្រឹក្សាជាតិគណនេយ្យបានចាប់ផ្តើមបង្កើត នឹងត្រូវអនុវត្តសាកល្បងនូវកម្មវិធីឃ្លាំមើលរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស ដើម្បីកាត់បន្ថយជាបណ្តើរៗនៃរបាយការណ៍ហិរញ្ញវត្ថុដែលមិនមានតម្លាភាពដែលនាំឱ្យមានព័ត៌មានមិនគួរទុកចិត្ត និងមិនអនុលោមតាមស្តង់ដាគណនេយ្យដែលបានកំណត់។

## II. គោលបំណងនៃកម្មវិធី

កម្មវិធីឃ្លាំមើលរបាយការណ៍ហិរញ្ញវត្ថុ (“Financial Reporting Surveillance Program-FRSP”) ត្រូវបានបង្កើតឡើងក្នុងគោលបំណង ដឹកនាំក្រុមហ៊ុន សមាគម បំពេញតាមតម្រូវការដែលមានចែងក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជាពិសេសការកាន់បញ្ជីគណនេយ្យ, ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដាគណនេយ្យនៅកម្ពុជាដើម្បីផ្តល់ដល់វិនិយោគិន និងភាគីពាក់ព័ន្ធនូវរបាយការណ៍ហិរញ្ញវត្ថុដែលអាចទុកចិត្តបាន និងមានសារៈប្រយោជន៍គ្រប់គ្រាន់សម្រាប់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច។ លើសពីនេះ, កម្មវិធីនេះនឹងជួយបង្កើនទំនុកចិត្តរបស់វិនិយោគិន និងអ្នកពាក់ព័ន្ធដទៃទៀតលើតម្លាភាព, សុចរិតភាព, និងគុណភាពនៃរបាយការណ៍ហិរញ្ញវត្ថុ នៅកម្ពុជា។

FRSP ជាកាតព្វកិច្ចរបស់អគ្គនាយកក្រុមហ៊ុនដែលត្រូវដឹងនិងអនុវត្តទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុ អនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងពន្ធដារ ជាពិសេសរបាយការណ៍ហិរញ្ញវត្ថុដែល÷

១. គោរពតាមស្តង់ដាគណនេយ្យជាធរមាននៅកម្ពុជា

២. បង្ហាញនូវភាពពិតនិងត្រឹមត្រូវនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុលទ្ធផលលម្អិត និង លំហូរសាច់ប្រាក់ របស់ក្រុមហ៊ុន។

## III. នាយកដ្ឋានអនុវត្ត

នាយកដ្ឋានអនុលោមភាព និងត្រួតពិនិត្យ (Compliance and Inspection Department-CID) នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ ទទួលខុសត្រូវក្នុងការអនុវត្តការគ្រប់គ្រងកម្មវិធីឃ្លាំមើលរបាយការណ៍ហិរញ្ញវត្ថុ (FRSP) ដែលមានក្នុងនោះការិយាល័យអនុលោមភាពគឺជាអ្នកទទួលបន្ទុកផ្ទាល់។ នៅក្រោមកម្មវិធីនេះ, របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសដែលបានជ្រើសរើសដោយ ក្រុមប្រឹក្សាជាតិគណនេយ្យនឹងត្រូវរងការត្រួតពិនិត្យ សម្រាប់ការអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម (ច្បាប់គណនេយ្យនិងសវនកម្មថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦) និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន នៅប្រទេសកម្ពុជា។

## IV. មុខងារ និងភារកិច្ច

ដើម្បីលើកកម្ពស់តម្លាភាព ក្រុមប្រឹក្សាជាតិគណនេយ្យនឹងផ្សព្វផ្សាយរបាយការណ៍សកម្មភាពសង្ខេប និងរបកគំហើញរបស់កម្មវិធីកម្មវិធីឃ្លាំមើលរបាយការណ៍ហិរញ្ញវត្ថុក្នុងដំណាក់កាលផ្លូវការ និង ត្រូវពិចារណាដោយយកចិត្តទុកដាក់អំពីការផ្សព្វផ្សាយរបាយការណ៍លទ្ធផលទាំងនេះក្នុងដំណាក់កាលសាកល្បងផងដែរ។ របាយការណ៍ទាំងនេះមានគោលបំណងជួយដល់ក្រុមហ៊ុននានាជៀសវាងហានិភ័យទាំងឡាយដែលកើតមានឡើងនិងកែលម្អរបាយការណ៍ហិរញ្ញវត្ថុដោយបង្កើនការយល់ដឹងអំពីការអនុវត្ត និងការបកស្រាយស្តង់ដាគណនេយ្យទៅនឹងលក្ខខណ្ឌតម្រូវនានានៃច្បាប់។

ដើម្បីណែនាំប្រធានក្រុមហ៊ុន និងអ្នករៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្សេងទៀត ក្រុមប្រឹក្សាជាតិគណនេយ្យ និងធ្វើការផ្សព្វផ្សាយពីគោលការណ៍ណែនាំការអនុវត្តរបាយការណ៍ហិរញ្ញវត្ថុដែលផ្តោតលើកម្មវិធីឃ្លាំមើលរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំខាងមុខនេះ។ ការពិនិត្យឡើងវិញលើរបាយការណ៍ហិរញ្ញវត្ថុ មិនថា ប្រធានក្រុមហ៊ុន ឬជានាយកប្រតិបត្តិ ឬនាយកមិនប្រតិបត្តិ គួរយកចិត្តទុកដាក់លើសមត្ថភាព និងភាពឧស្សាហ៍ព្យាយាម ក្នុងការពិនិត្យឡើងវិញលើរបាយការណ៍ហិរញ្ញវត្ថុ ដែលត្រូវបានបង្ហាញជូនម្ចាស់ភាគហ៊ុន ហើយបន្ទាប់មកជូនដំណឹងមកក្រុមប្រឹក្សាជាតិគណនេយ្យ។

លើសពីនេះ, នាយកក្រុមហ៊ុនគួរតែស្វែងយល់ និងសាកសួរអំពីទម្រង់ និងខ្លឹមសារនៃរបាយការណ៍-

ហិរញ្ញវត្ថុ ដើម្បីធានាថាព័ត៌មានហិរញ្ញវត្ថុដែលបានបង្ហាញមានភាពច្បាស់លាស់ពេញលេញនិងសមស្រប។ ទោះបីជាមិនមែនជាអ្នកជំនាញគណនេយ្យក៏ដោយ,នាយកក្រុមហ៊ុនគួរតែសាកសួរទៅគណនេយ្យករ ឬ អ្នករៀបចំរបាយការណ៍ហិរញ្ញវត្ថុពេលដែលមានចម្ងល់ទាក់ទងនឹងខ្លឹមសារនៃការរៀបចំ។

ពាក់ព័ន្ធនឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ, នាយកក្រុមហ៊ុនមិនត្រូវបានគេរំពឹងថា ជាអ្នកជំនាញគណនេយ្យទេ ប៉ុន្តែគួរតែមានចំណេះដឹងគ្រប់គ្រាន់អំពីគោលការណ៍គណនេយ្យ និងការអនុវត្តដើម្បីអនុវត្តការត្រួតពិនិត្យកម្រិតខ្ពស់នៃរបាយការណ៍ហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព។ បើមិនដូច្នេះទេនាយកក្រុមហ៊ុនគួរតែស្វែងរកជំនួយចូលរួមវគ្គបណ្តុះបណ្តាល។

ការតែងតាំងអ្នកគ្រប់គ្រង÷ នាយកគួរតែធានាថាថ្នាក់ដឹកនាំក្រុមហ៊ុនដូចជាប្រធាននាយកប្រតិបត្តិ (នាយកប្រតិបត្តិ)និងប្រធានផ្នែកហិរញ្ញវត្ថុ (CFO)មានចំណេះដឹងសមត្ថភាពបទពិសោធន៍និងភាពស្មោះត្រង់គ្រប់គ្រាន់ក្នុងការបំពេញតួនាទីរបស់ខ្លួន។

នៅក្នុងរបាយការណ៍ប្រចាំឆ្នាំត្រូវតែមានការធានាពីនាយកប្រតិបត្តិ និងCFO។ម្យ៉ាងវិញទៀត, របាយការណ៍ហិរញ្ញវត្ថុត្រូវបានរក្សាទុកយ៉ាងត្រឹមត្រូវព្រមទាំងផ្តល់នូវទស្សនៈពិតនិងត្រឹមត្រូវអំពីប្រតិបត្តិការនិងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ មុខងារហិរញ្ញវត្ថុដែលមានលក្ខណៈប្រកួតប្រជែង និងមានធនធានគ្រប់គ្រាន់គឺ÷

១.នាយកក្រុមហ៊ុនគួរធានាថា ការគ្រប់គ្រងរក្សាមុខងារហិរញ្ញវត្ថុដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលអាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលមានគុណភាពខ្ពស់

២.គណនេយ្យករ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់គួរតែត្រូវបានជ្រើសរើស និងផ្តល់ការបណ្តុះបណ្តាលដែលពាក់ព័ន្ធ ដើម្បីរក្សាឱ្យពួកគេនូវភាពរីកចម្រើននូវចំណេះដឹងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ ការប្រើប្រាស់ជំនួយខាងក្រៅ នាយកក្រុមហ៊ុនអាចស្វែងរកដំបូន្មានគណនេយ្យ ប្រភពធនធានដល់អ្នកផ្តល់សេវាគណនេយ្យជំនាញក្នុងការរក្សាគណនេយ្យនិងកំណត់ត្រាផ្សេងទៀតនិងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ ទោះជាយ៉ាងណាក៏ដោយពួកគេនៅតែមានទំនួលខុសត្រូវហើយត្រូវធានាថាដំបូន្មាន ឬសេវាកម្ម ទាំងនោះត្រូវបានផ្តល់ដោយមនុស្សដែលមានសមត្ថភាពសមស្របជាមួយនឹងកម្រិតជំនាញនិងចំណេះដឹងសមស្របទៅតាមស្តង់ដាគណនេយ្យ។

សវនករឯករាជ្យ តម្រូវឱ្យទាក់ទងជាមួយអ្នកដែលទទួលបន្ទុកអភិបាលកិច្ច លើលទ្ធផលនៃការធ្វើសវនកម្មសំខាន់ៗរួមទាំងមូលហេតុដែលពួកគេគិតថាការអនុវត្តគណនេយ្យសំខាន់ៗមិនសមស្របនឹងកាលៈទេសៈជាក់លាក់របស់ក្រុមហ៊ុនមុនពេលចេញរបាយការណ៍សវនកម្ម។ នាយកក្រុមហ៊ុនមិនគួរពឹងផ្អែកលើសវនករឯករាជ្យក្នុងការបង្កើតគំនិតផ្ទាល់ខ្លួនរបស់ពួកគេលើរបាយការណ៍ហិរញ្ញវត្ថុទេ។

## V. ចំណុចត្រូវវាយតម្លៃ

| ឯកសារវាយតម្លៃ | √ | ពិន្ទុ | មតិយោបល់ |
|---|---|---|---|
| ១.ការកាន់បញ្ជីគណនេយ្យ | | ១០០ | ≤៧០% មិនទទួលរងការពិន័យ |
| ១.១បញ្ជីគណនេយ្យមានជាអាទិ៍÷ | | | |
| • បញ្ជី/សៀវភៅទិញ | | ២៥ | |
| • បញ្ជី/សៀវភៅលក់ | | ២៥ | |
| • បញ្ជី/សៀវភៅទទួលប្រាក់ | | ២០ | |
| • បញ្ជី/សៀវភៅបង់ប្រាក់ | | ២០ | |
| • បញ្ជី/សៀវភៅចាំបាច់ផ្សេងទៀត...... | | ១០ | |
| ២.ភាសា÷ | | ១០០ | ≤៧០% មិនទទួលរងការពិន័យ |
| • របាយការណ៍ហិរញ្ញវត្ថុ ត្រូវប្រើជាភាសាខ្មែរ | | ៦០ | |
| • កម្មវិធីគណនេយ្យកុំព្យូទ័រ អាចប្រើជាភាសាខ្មែរ ឬ អង់គ្លេស | | ១៥ | |
| • បញ្ជី/សៀវភៅ អាចប្រើជាភាសាខ្មែរ ឬ អង់គ្លេស | | ១៥ | |
| • ឯកសារគាំទ្រ÷ត្រូវមានភាសាខ្មែរ ឬ លើកលែងឯកសារពីដៃគូបរទេស | | ១០ | |
| ៣.រូបិយបណ្ណ | | ១០០ | ≤៧០% មិនទទួលរងការពិន័យ |
| • របាយការណ៍ហិរញ្ញវត្ថុ ត្រូវប្រើជាប្រាក់រៀល | | ៦០ | |
| • កម្មវិធីគណនេយ្យកុំព្យូទ័រ អាចប្រើជាប្រាក់រៀល ឬ ប្រាក់ដុល្លារ | | ២០ | |
| • បញ្ជី/សៀវភៅ អាចប្រើជាប្រាក់រៀល ឬប្រាក់ដុល្លារ | | ២០ | |
| ៤.ការិយបរិច្ឆេទគណនេយ្យ÷ | | ១០០ | ≤៧០% មិនទទួលរងការ |

| | | | |
|---|---|---|---|
| | | | ពិន័យ |
| • ១ មករា ដល់៣១ ធ្នូនៃឆ្នាំដដែល | | ១០០ | |
| • ការិយបរិច្ឆេទគណនេយ្យខុសពីឆ្នាំសារពើពន្ធដែលបាន អនុញ្ញាតពី ក.ជ.គ. | | ១០០ | |
| **៥.ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ** | | **១០០** | ≤៧០% មិនទទួលរងការពិន័យ |
| ៥.១ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា | | ១០០ | |
| ៥.២. ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) | | ១០០ | |
| **៦.ការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ** | | | |
| ៦.ក. សហគ្រាសជាប់លក្ខខណ្ឌស្វ័យប្រវត្តិ | | **១០០** | ≤៧០% មិនទទួលរងការពិន័យ |
| ៦.ក.១. សហគ្រាសសាធារណៈ | | ១០០ | |
| ៦.ក.២. សហគ្រាសទទួលខុសត្រូវជាសាធារណៈ | | ១០០ | |
| ៦.ក.៣. គម្រោងដែលបានលក្ខណៈសម្បត្តិគ្រប់គ្រាន់ | | ១០០ | |
| ៦.ខ. សហគ្រាសជាប់លក្ខខណ្ឌ | | **១០០** | ≤៧០% មិនទទួលរងការពិន័យ |
| ៦.ខ.១. ផលរបរប្រចាំឆ្នាំចាប់ពី ៤ ប៊ីលានរៀល | | ៤០ | |
| ៦.ខ.២. តម្លៃទ្រព្យសកម្មចាប់ពី ៣ ប៊ីលាន រៀល | | ៣០ | |
| ៦.ខ.៣. ចំនួនកម្មករនិយោជិកចាប់ពី ១០០ នាក់ឡើងទៅ | | ៣០ | |

## VI. ទោសទណ្ឌ

### ១. ទឹកប្រាក់ពិន័យអន្តរការណ៍

| ល.រ | អំពើល្មើស | អ្នកជាប់ពន្ធធំ | អ្នកជាប់ពន្ធមធ្យម |
|---|---|---|---|
| ក | ការប្រើកាលបរិច្ឆេទគណនេយ្យខុសពីច្បាប់ស្តីពីគណនេយ្យនិងសវនកម្មដោយគ្មានការអនុញ្ញាត | ២ ០០០ ០០០ | ១ ៥០០ ០០០ |
| ខ | ការមិនប្រើភាសាខ្មែរនៅក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ | ២ ០០០ ០០០ | ១ ៥០០ ០០០ |
| គ | ការប្រើរូបិយប័ណ្ណនៅក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍-ហិរញ្ញវត្ថុ ក្រៅពីប្រាក់រៀល ដោយគ្មានការអនុញ្ញាត | ២ ០០០ ០០០ | ១ ៥០០ ០០០ |
| ឃ | ការមិនដាក់ឬភាពយឺតយ៉ាវក្នុងដាក់របាយការណ៍ហិរញ្ញវត្ថុមកអគ្គលេខាធិការដ្ឋាននៃ ក.ជ.គ. | ២ ០០០ ០០០ | ២ ០០០ ០០០ |
| ង | ការមិនកាន់បញ្ជីគណនេយ្យ | ១០ ០០០ ០០០ | ១០ ០០០ ០០០ |
| ច | ការមិនរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន | ១០ ០០០ ០០០ | ៨ ០០០ ០០០ |
| ឆ | ការខកខានមិនដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ២០ ០០០ ០០០ | ១៦ ០០០ ០០០ |
| ជ | ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមានសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ | ១០ ០០០ ០០០ | ៨ ០០០ ០០០ |
| ឈ | ការមិនរក្សាទុកឯកសារគណនេយ្យតាមច្បាប់កំណត់ | ១០ ០០០ ០០០ | ៨ ០០០ ០០០ |

## ២. ករណីមិនរាងចាល

➢ ក្នុងករណីមិនរាងចាល បុគ្គលល្មើសត្រូវទទួលរងការពិន័យអន្តរការណ៍បន្ថែមជាប្រាក់ដូចខាងក្រោម÷

- មិនរាងចាលលើកទី១ ÷ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍គុណនឹងពីរដងនៃប្រាក់ពិន័យអន្តរការណ៍ ដែលបង់លើកដំបូង
- មិនរាងចាលលើកទី២÷ ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍គុណនឹងពីរដងនៃប្រាក់ពិន័យអន្តរកាណ៍ ដែលបង់ក្នុងករណីមិនរាងចាលលើកទី១
- មិនរាងចាលលើកទី ៣ ÷ ក.ជ.គ. សម្រេច ព្យួរ ឬដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្មចំពោះគណនេយ្យករនិងសវនករ។ ក.ជ.គ.នឹងរៀបចំលិខិតស្នើសុំទៅក្រសួងស្ថាប័ន
- មានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់វិធានការស្របតាមច្បាប់ជាធរមានចំពោះសហគ្រាស និង អង្គភាពមិនស្វែងរកប្រាក់ចំណេញ។

## ៣. ការយឺតយ៉ាវមិនបានបង់ប្រាក់ពិន័យអន្តរការណ៍តាមការកំណត់

➢ ក្នុងករណីបុគ្គលល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍÷

- ក្នុងរយៈពេល៣០ថ្ងៃ ÷ ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវដំឡើងជាពីរដង
- លើសពី ៦០ថ្ងៃ÷ ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នេះនឹងត្រូវដំឡើងជាបីដង
- ផុតរយៈពេល ៩០ថ្ងៃ÷ ក.ជ.គ. នឹងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

ចំណាំ ÷ រយៈពេល ៣០(សាមសិប) ថ្ងៃ ៦០(ហុកសិប) ថ្ងៃ និង ៩០(កៅសិប) ថ្ងៃ ចាប់គិតពីថ្ងៃបុគ្គលល្មើស ទទួលបាន លិខិតជូនដំណឹងអំពីការបង់ប្រាក់ពិន័យអន្តរកាណ៍ពី ក.ជ.គ.

## ៤. បណ្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចពិន័យអន្តរការណ៍

